# គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ របស់ជនជាតិដើមភាគតិចក្នុងខេត្តមណ្ឌលគីរី

**S5-P2**








## សហការណ៍ជាមួយ

សហការណ៍ជាមួយសាលាឃុំពូជ្រៃ មន្ទីរបរិស្ថាន មន្ទីរអប់រំ និងសាលាខេត្តមណ្ឌលគីរី

## អនុវត្តដោយ

ស.អ.ជ.ម
MIPAD
Mondulkiri Indigenous People Association for Development

## ឧបត្ថមថវិកាដោយ

PLAN INTERNATIONAL

តាមរយ:គម្រោង

គម្រោងTA8179-CAM

យោង លិខិតលេខ ៣៦៣៧ MEF/DiC ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

➢ ទីតាំង៖

➢ ខេត្តមណ្ឌលគីរី ស្ថិតនៅប៉ែកឥសាន្តនៃប្រទេសកម្ពុជា
➢ មានផ្ទៃដីធំទូលាយ ប៉ុន្តែមានចំនួនប្រជាជនតិចតួច
➢ មានធម្មជាតិដ៏ស្រស់ស្អាត គ្របដណ្តប់ដោយព្រៃភ្នំយ៉ាងក្រាស់ ទឹកជ្រោះធ្លាក់យ៉ាងខ្ពស់ និងជាតំបន់ខ្ពង់រាបមានពណ៌បៃតង។



# ការអភិរក្សព្រៃឫស្សី និងវាលស្បូវសម្រាប់ជនជាតិដើមភាគតិច ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ





ស្បូវសម្រាប់ប្រកដំបូល



ផ្ទះខ្ទងអណ្ដើកសាងសង់អំពីឫស្សី និង ស្បូវ

ឫស្សីសម្រាប់តួផ្ទះ

ប្រធានបទទី១៖  ការអនុវត្តជាលក្ខណៈប្រពៃណី/ជនជាតិដើមភាគតិចដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

ពាក្យគន្លឹះ៖  ព្រៃឬស្សី/វាលស្រូវ/ប្រពៃណីលំនៅដ្ឋាន/ចំណេះដឹងក្នុងតំបន់/ការគ្រប់គ្រងប្រកបដោយនិរន្តរភាព



ព្នងគឺជាក្រុមជនជាតិដើមភាគតិច ដែលភាគច្រើនរស់នៅខេត្តមណ្ឌលគិរី។ ពួកគេរស់នៅជាក្រុមក្នុងតំបន់ខ្ពង់រាប នៃប្រទេសកម្ពុជា ដោយប្រើភាសាព្នងជាភាសាដើមកំណើត។ ជាប្រពៃណីរបស់ជនជាតិព្នងគឺសង់លំនៅដ្ឋានពីឫស្សី និងដំបូលប្រក់ស្លឹកជាមួយនឹងផ្ទោងឈើ។







- លំនៅដ្ឋានស្ថិតនៅទីជម្រេលជើងភ្នំ ឆ្ងាយពីស្រែចម្ការ តែនៅជិតស្ទឹងងាយស្រួលដល់ការប្រើប្រាស់ទឹកនិងការចិញ្ចឹមសត្វ។
- ជាទម្លាប់ពួកគេសង់ជម្រកធ្វើពីឈើដែលខុសគ្នាទាំងស្រុងពីលំនៅដ្ឋានរាងជាដំបូលកោង។
- ជាប្រពៃណីជនជាតិព្នងតែងផ្លាស់ទីទៅតាមកន្លែងធ្វើចម្ការ ហើយឫស្សី/ស្បូវ និងវល្លិ៍ ជាវត្ថុធាតុដើមសម្រាប់សាងសង់លំនៅដ្ឋាន ព្រោះជាសំណង់សាមញ្ញ ងាយស្រួលសាងសង់ និងចំណាយពេលតិចផង។
- ប្រពៃណីចម្បងនៃភូមិដ្ឋានជនជាតិព្នងគឺសាងសង់លំនៅដ្ឋាននៅទីតាំងដែលសម្បូរទៅដោយព្រៃឫស្សី។



- លំនៅដ្ឋានដែលសាងសង់ពីឈើ តែងស្ថិតនៅតំបន់ទីជំរាលវាលទំនាបក្បែរស្ទឹង ហើយតែងតែរងគ្រោះដោយសារ ទឹកហូរខ្លាំង។
- ការប្រើប្រាស់ឬស្សី/ស្បូវ និងវល្លិ៍ គឺបន្សាំនឹងបរិស្ថានក្នុងតំបន់នោះ ដែលអាចធន់នឹងការប្រែប្រួលអាកាសធាតុ ឬហានិភ័យគ្រោះមហន្តរាយ។
- ព្រៃឬស្សី និងវាលស្បូវ គឺជាវត្ថុធាតុដើមដ៏សំខាន់ សម្រាប់ជនជាតិព្នង ដែលមានតម្លៃជាប្រពៃណី និងជាតម្រូវការសម្រាប់គ្រប់គ្រង និងការពារឱ្យមាននិរន្តរភាពធនធានទាំងនោះ។



# ៣- នាទីដែលពាក់ព័ន្ធក្នុងការអភិរក្សព្រៃឫស្សី ៖

- ការអភិរក្សព្រៃឫស្សី និងវាលឫស្សី ត្រូវបានបង្កើតឡើង ប៉ុន្តែអាស្រ័យលើប្រពៃណីទំនៀមទំលាប់ពីបុរាណ។
- ជនជាតិពួងបានយល់ដឹងអំពីការប្រើប្រាស់ដើមឫស្សី ដើម្បីឱ្យមានប្រសិទ្ធភាពប្រកបដោយនិរន្តរភាព ហើយច្រូតកាត់ស្បូវនៅកាលៈទេសៈមួយដ៏សមស្របនៃរដូវកាល។
- ចាស់ព្រឹទ្ធាចារ្យក្នុងភូមិបានអប់រំដល់កូនចៅពីរបៀបកាប់ដើមឫស្សី និងអំពីរបៀបច្រូតកាត់ស្បូវ សម្រាប់សាងសង់លំនៅដ្ឋានរបស់ខ្លួន។



- បច្ចុប្បន្ន ការអភិរក្សព្រៃឫស្សី ជាផ្នែកមួយនៃសហគមន៍ព្រៃឈើ ដើម្បីការពារព្រៃឈើក្រោមច្បាប់ ។ វាមានសារៈប្រយោជន៍សម្រាប់ជនជាតិដើមភាគតិច។ ការអភិរក្សព្រៃឫស្សី និងវាលឫស្សី បង្ហាញឱ្យឃើញជាលក្ខណៈប្រព័ន្ធអេកូឡូស៊ី និងផ្លូវច្បាប់។
- រហូតមកដល់ពេលនេះ គ្មានការស្រាវជ្រាវ ឬសិក្សាច្បាស់លាស់ណាមួយអំពីវាលឫស្សី ឬវាលទំនេរនៅលើខ្ពង់រាប ដែលមានប្រយោជន៍ដល់ជនជាតិដើមភាគតិច ឬដល់ប្រព័ន្ធអេកូឡូស៊ី។ ទីវាលមានតួនាទីសំខាន់ ក្នុងបរិបទការប្រែប្រួលអាកាសធាតុ។ ចំណេះដឹងជនជាតិភាគតិច បានបង្ហាញឱ្យឃើញថាទីវាល (វាលស្បូវវែងៗ) អាចការពារភាពហូរច្រោះ និងការរអិលបាក់ដីពីទីជំរាល។

# ការគំរាមកំហែង និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ៖



- ព្រៃឫស្សី និងទីវាលជាផ្នែកមួយនៃធនធានធម្មជាតិជាប្រពៃណីសម្រាប់ជនជាតិដើមភាគតិចដើម្បីបន្សាំនឹងបរិស្ថានក្នុងតំបន់នោះ និងកំណើនហានិភ័យគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ដូចជាភ្លើងឆេះព្រៃ



- វិធានការបន្សាំ៖

- វិធានការអភិរក្សដ៏សមរម្យមួយ នឹងធ្វើឱ្យព្រៃឫស្សី និងទីវាលរីកដុះដាលឡើងវិញជាលក្ខណៈធម្មជាតិ។
- វិធាននេះអាចជួយដល់ជនជាតិដើមភាគតិចក្នុងការសាងសង់លំនៅដ្ឋានពីឫស្សី និងស្បូវជាប្រចាំ។ ទាំងនេះគឺជាធនធានយ៉ាងសំខាន់សម្រាប់ពួកគេក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។
- ការបាត់បង់ធនធានព្រៃឫស្សី និងស្បូវ បានកាត់បន្ថយសមត្ថភាពយ៉ាងច្រើនក្នុងការបន្សាំនឹងការប្រែប្រួល អាកាសធាតុ។

# ៦ សារៈប្រយោជន៍៖



- វិធានការអភិរក្សដ៏សមរម្យមួយ នៃព្រៃឫស្សី និងទីវាល អាចជួយដល់ជនជាតិដើមភាគតិច រួមទាំងស្ត្រីបន្សាំ នឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ។
- ទំពាំងអាចរកបានពី ព្រៃឫស្សី គឺជាធនធានយ៉ាងសំខាន់សម្រាប់ធ្វើជាអាហាររបស់ជនជាតិដើមភាគតិច។





“ក”

- ជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគីរី បានជ្រើសរើសដីចម្ការរបស់ខ្លួន ដែលមានព្រៃឫស្សីព័ទ្ធជុំវិញ ធ្វើជារបងធម្មជាតិសម្រាប់ការពារភោគផលដំណាំពីកំលាំងខ្យល់។
- ចំណេះដឹងអំពីការគ្រប់គ្រងព្រៃឫស្សី និងទីវាលឱ្យមាននិរន្តរភាព គឺនៅមានកម្រិត ដើម្បីបង្កើនទិន្នផលពាណិជ្ជកម្ម នៅក្នុងចំណោមជនជាតិដើមភាគតិច។







- ទំហំនៃព្រៃឫស្សី និងទីវាល មានសារៈប្រយោជន៍យ៉ាងសំខាន់ ដូចជាជួយកាត់បន្ថយការហូរច្រោះ និងការរអិលបាក់ដីនៅពេលអនាគត។

**គំនិតសម្រាប់ការពង្រីកបន្ថែម៖**

ជួយគាំទ្រដល់ភូមិដ្ឋានជនជាតិដើមភាគតិច ដើម្បីការពារដ៏សមស្របសម្រាប់ផ្ទៃដីព្រៃឫស្សី នឹងផ្ទៃដីទីវាល។

ស្វែងរកការគាំទ្រជាលក្ខណៈជាតិសម្រាប់ការចង្អុលបង្ហាញជាផ្លូវការនៃផ្ទៃដីព្រៃឫស្សី និងផ្ទៃដីទីវាល។

អង្គការមិនមែនរដ្ឋាភិបាលឬស្ថាប័នផ្សេងៗ គួរសិក្សាឱ្យស៊ីជម្រៅទៅលើការទទួលខុសត្រូវ និងការគ្រប់គ្រងព្រៃឫស្សី និងទីវាលប្រកបដោយនិរន្តរភាព តាមរយៈចំណេះដឹងជាប្រពៃណី។








សូមអរគុណ
ឈ្មោះក្រាំង ផុន្នី
ទូរស័ព្ទ៖ 0889005686 - 099266766
អ៊ីមែល៖ phonnykrang@gmail.com